00224193

D99/3/8

**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**

**សំណុំរឿងលេខ:** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ.០២)

**ដាក់តម្កល់ជូន:** អង្គបុរេជំនុំជម្រះ

**កាលបរិច្ឆេទដាក់ឯកសារ:** ១៦ កញ្ញា ២០០៨

**ភាគីអ្នកតម្កល់:** មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

**ភាសាដើម:** ភាសាបារាំង

**ប្រភេទឯកសារ:** សាធារណៈ

---

**ចម្លើយរបស់ក្រុមការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងដីកា**

**ដំណោះស្រាយចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨**

---

<u>បញ្ជូនដោយ:</u>

**មេធាវីរបស់លោក កាំង ហ្កេកអ៊ាវ**

លោក ការ សាវុត្ថ

លោក François ROUX

<u>បញ្ជូនទៅ:</u>

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោកចៅក្រម ប្រាក់ គីមសាន ប្រធាន

លោកចៅក្រម Rowan DOWNING

លោកចៅក្រម ន័យ ថុល

លោកស្រីចៅក្រម Katinka LAHUIS

លោកចៅក្រម ហួត វុទ្ធី

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 16 / 09 / 2008
ម៉ោង (Time/Heure): 14 : 30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 16 / 09 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ty

**ជូនចំពោះអង្គបុរេជំនុំជម្រះ**

1. ក្រុមការពារក្តីចាត់ទុកថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាសម្អាងលើការបកស្រាយដោយភ័ន្តច្រឡំចំពោះវិធានដែលចែងអំពីនីតិវិធីដែលអាចអនុវត្តន៍បាន នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("អ.វ.ត.ក") ហើយដែលនៅចុងបញ្ចប់នៃនីតិវិធីនោះ សហព្រះរាជអាជ្ញាជាអ្នកស្នើសុំ ហើយចៅក្រមជាអ្នកសម្រេច[1]។
2. ដូច្នេះ ដោយសម្រេចមិនប្រកាន់យកនូវសេចក្តីសន្និដ្ឋានមួយចំនួនដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតមិនបានប្រព្រឹត្តកំហុសផ្លូវច្បាប់ណាមួយទេ ហើយការសម្រេចនេះធ្វើឡើងដោយរក្សាសិទ្ធិឲ្យមានការត្រួតពិនិត្យជាយថាហេតុរបស់អង្គបុរេជំនុំជម្រះ។
3. នៅក្នុងនីតិវិធីដែលដឹកនាំដោយចៅក្រម គឺចៅក្រមដែលជាអ្នកកំណត់ក្របខណ្ឌនៃការជំនុំជម្រះក្តី ហើយមិនមែនជាព្រះរាជអាជ្ញាទេ។
4. ម៉្យាងទៀត ក្រុមការពារក្តីសូមលើកហេតុផលថា សំណើដែលធ្វើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះគួរតែលើកឡើងនៅក្នុងពេលជំនុំជម្រះក្តីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដោយហេតុដូច្នេះ សហព្រះរាជអាជ្ញាមិនចាំបាច់ប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ របស់សហចៅក្រមស៊ើបអង្កេតនោះទេ។
5. នៅក្នុងលក្ខខណ្ឌទាំងនេះ ក្រុមការពារក្តីចាត់ទុកថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាគឺពិតជាមិនសមស្រប៖ តើសហព្រះរាជអាជ្ញាអាចនិយាយថា ឌុច អាចរួចផុតពីបទចោទប្រកាន់ដោយរបៀបណា នៅពេលដែល ឌុច បានទទួលស្គាល់ជាច្រើនលើកច្រើនសារ នូវភាពទទួលខុសត្រូវរបស់ខ្លួនចំពោះបទឧក្រិដ្ឋដែលបានប្រព្រឹត្តនៅ ស.២១ ហើយគាត់បានសម្តែងនូវវិប្បដិសារីដ៏ស្មោះស្ម័គចំពោះជនរងគ្រោះនោះ?
6. ជាការពិតណាស់ដែលម្តងហើយម្តងទៀត សហព្រះរាជអាជ្ញាភ្លេចគិតដល់ធាតុផ្សំចំបងៗទាំងនេះនៃសំណុំរឿង។
7. ក៏ដូចគ្នាដែរ នៅក្នុងដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន សហព្រះរាជអាជ្ញាក៏មិនបានផ្តល់នូវការគិតគូរពិចារណាមួយឡើយ ចំពោះការស៊ើបសួរដល់ទីកន្លែង ដែលជាកិច្ចស៊ើបសួរផ្នែកតុលាការមួយដ៏ចម្បង

---

[1] វិធាន ៦៧ (១) នៃវិធានផ្ទៃក្នុងចែងថា សហចៅក្រមស៊ើបអង្កេត *"មិនត្រូវបានចងដោយដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាឡើយ"*។ សូមអានផងដែរនូវមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (CPPRC) ដែលចែងថា៖ *"ចៅក្រមស៊ើបសួរមិនត្រូវជាប់កាតព្វកិច្ច គោរពតាមដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញាទេ។"*។

ហើយដែលអាចកើតមានឡើង សម្រាប់ជាប្រយោជន៍ដ៏សំខាន់ដល់យុត្តិធម៌និងដល់ជនរងគ្រោះ តែដោយសារមានឆន្ទៈធ្វើកិច្ចសហប្រតិបត្តិការរបស់ ឌុច តែប៉ុណ្ណោះ។

8. ម្យ៉ាងទៀត ក្រុមការពារក្តីចាត់ទុកថា បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាមុខជានឹងធ្វើឱ្យមានភាពយឺតយ៉ាវយ៉ាងខ្លាំងដល់ការបើកការជំនុំជម្រះក្តី។

9. ជាការពិតណាស់ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា ឌុច ត្រូវតែចោទដោយការចោទប្រកាន់ថ្មីៗនោះ បញ្ហានេះនឹងទាមទារជាចាំបាច់ឱ្យ ឌុច បង្ហាញខ្លួនជាថ្មី ឬមួយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ឬមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ ដើម្បីឱ្យ ឌុច មានលទ្ធភាពបង្ហាញនូវការកត់សម្គាល់របស់ខ្លួនចំពោះការចោទប្រកាន់ថ្មីមួយឬច្រើន។

10. ដូច្នេះ រឿងទាំងនេះក៏មានន័យផងដែរថា ការស៊ើបអង្កេតនឹងបន្តធ្វើ ដើម្បីអនុញ្ញាតជាអាទិ៍ឱ្យក្រុមការពារក្តី ឬក៏ភាគីដើមបណ្តឹងរដ្ឋប្បវេណី ស្នើនូវកិច្ចស៊ើបសួរបន្ថែមទៅលើបទចោទប្រកាន់ថ្មីៗ។

11. ដូច្នេះ ដោយពិតប្រាកដទៅ រឿងទាំងនេះមានន័យថា ការបើកការជំនុំជម្រះក្តីនឹងពិតជាត្រូវពន្យារពេលជាច្រើនខែ។

12. ក្រុមការពារក្តីសូមកត់សម្គាល់ថា បន្ទាប់ពីការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេលជាង ៩ ឆ្នាំដែលជាការផ្ទុយទៅនឹងស្តង់ដាជាតិនិងអន្តរជាតិ និងបន្ទាប់ពីការស៊ើបអង្កេតអស់រយៈពេលមួយឆ្នាំ ដែល ឌុច បានធ្វើសហប្រតិបត្តិការដោយគ្មានលក្ខខណ្ឌ ហើយដែលសហព្រះរាជអាជ្ញាបានចូលរួមប្រកបដោយអត្ថប្រយោជន៍នោះ សំណុំរឿងបានរៀបចំរួចជាស្រេច (លើកលែងតែការបកប្រែ)។

13. ដូច្នេះ នៅពេលនេះ បញ្ហាសមហេតុផលតែមួយគត់ ហើយដែលសហព្រះរាជអាជ្ញាគួរតែប្រកាសឱ្យដឹង គឺ៖ ទាំងសម្រាប់ផលប្រយោជន៍របស់ ឌុច ខ្លួនឯងក៏ដូចជាសម្រាប់ជនរងគ្រោះ តើការជំនុំជម្រះក្តីរបស់ ឌុច នឹងបើកធ្វើនៅពេលណា?

14. ដោយហេតុនេះ ក្រុមការពារក្តីចាត់ទុកថា គឺមិនមែនជាកាលៈទេសៈដែលត្រូវឆ្លើយទៅនឹងទឡ្ហីករណ៍ដែលលើកឡើងដោយសហព្រះរាជអាជ្ញានៅក្នុងបណ្តឹងឧទ្ធរណ៍របស់ខ្លួននោះទេ ហើយការពិភាក្សាលើទឡ្ហីករណ៍ទាំងនោះអាចគួរឱ្យចាប់អារម្មណ៍ទាក់ទងនឹងផ្នែកអាកាដេមិច ប៉ុន្តែពិតជាមិនគួរឱ្យចាប់អារម្មណ៍នៅដំណាក់កាលនៃនីតិវិធីនេះទេ។

15. ដោយហេតុដូច្នេះ ក្រុមការពារក្ដីសូមស្នើទៅអង្គបុរេជំនុំជម្រះ ឲ្យបដិសេធបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាថាគ្មានមូលដ្ឋានច្បាប់ ហើយបញ្ជូនសំណុំរឿងដោយគ្មានពន្យារពេល ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បី ឲ្យ ឌុច អាចទទួលបាននូវការជំនុំជម្រះក្ដី[2]។

16. ប៉ុន្តែ ក្រុមការពារក្ដីសូមរក្សាសិទ្ធិធ្វើការពិភាក្សានៅក្នុងពេលសវនាការជំនុំជម្រះក្ដី លើចំណុចនានានៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខ្លួនមិនមានការយល់ព្រម។

## តាមរយៈហេតុផលទាំងនេះ

17. ដោយឃើញធាតុផ្សំទាំងអស់នេះ ក្រុមការពារក្ដីសូមស្នើដោយគោរព ទៅអង្គបុរេជំនុំជម្រះ ឲ្យ៖

- **បដិសេធ**បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាថាគ្មានមូលដ្ឋានច្បាប់ ដោយមិនចាំបាច់មានសវនាការឡើយ។

ដោយបានឃើញវិធាន ២១ (៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក
មាត្រា ៣៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក
មាត្រា ៩ (៣) និង ១៤ (៣) (គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

- **បញ្ជូន**សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឲ្យ ឌុច អាចទទួលបាននូវការជំនុំជម្រះក្ដីភ្លាមៗ។

## សូមរក្សាសិទ្ធិគ្រប់បែបយ៉ាង

---

[2] សូមអានវិធាន ២១ (៤) នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក, មាត្រា ៣៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, និងមាត្រា ៩ (៣) និង ១៤ (៣) (គ) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។

00224197

[០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស(អ.ប.ជ.០២)]

D99/3/8

| | | | |
|---|---|---|---|
| ១០-៩-២០០៧ | សម្រាប់មេធាវីទាំងពីររូប<br>មេធាវីម្នាក់ក្នុងចំណោមមេធាវី<br>ទាំងពីររូប | ភ្នំពេញ | [signature] |
| កាលបរិច្ឆេទ | ឈ្មោះ ការ សាវុត្ថ | ទីកន្លែង | ហត្ថលេខា |